មាតិកា

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៩-៦-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៦០២/១៩១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ១៥៦៧

០៩-៦-២០០២ -ព្រះរាជក្រឹត្យនស/រកត/០៦០២/១៩២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ១៥៧៥

០៩-៦-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៦០២/១៩៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌបច្ចេកទេសថ្នាក់បឋម ១៥៨៣

០៩-៦-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៦០២/១៩៤ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌភ្នាក់ងារបច្ចេក ទេស ១៥៨៩

១០-៦-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៦០២/១៩៥ ស្តីពីការបំពាក់មេដាយការពារជាតិ ជូននាយទាហាន ថ្នាក់ឧត្តមសេនីយ៍ ចំនួន ០៤ រូប ក្នុង ០១រូប១ មេដាយសិរីវឌ្ឍចំនួន ០២ គ្រឿង មេដាយប្រាក់ចំនួន ០២ គ្រឿង និងមេដាយមាសចំនួន ០២ គ្រឿង និងមេដាយការពារជាតិជូននាយទាហានថ្នាក់វរសេនីយ៍ចំនួន ៩៩១ រូប ១៥៩៤

១០-៦-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៦០២/១៩៦ ស្តីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម **នាង ស៊ីឌុំខ** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ១៦៣១

១៩-៦-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៦០២/១៩៨ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ១៦៣២

១៩-៦-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៦០២/១៩៩ ស្តីពីការតែងតាំង ឯកឧត្តម **នុត សារាន** ឧត្តមមន្ត្រីថ្នាក់លេខ ២ បច្ចុប្បន្នជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានឋានៈស្មើរដ្ឋលេខាធិការ ឱ្យទទួលបន្ថែមជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ១៦៣៤

II- រាជរដ្ឋាភិបាល

១- អនុក្រឹត្យ

១៧-៦-២០០២ - អនុក្រឹត្យលេខ ៥៧ អនក្រ.បក ស្តីពីការបង្កើតការិយាល័យអនុព័ន្ធយោធា ១៦៣៥

១៧-៦-២០០២ - អនុក្រឹត្យលេខ ៥៨ អនក្រ.បក ស្តីពីការទទួលស្គាល់ការកែប្រែមហាវិទ្យាល័យ គ្រប់គ្រង និង នីតិសាស្ត្រទៅជាសាកលវិទ្យាល័យ បៀលប្រាយ ១៦៣៦

នស/រកត/០៦០២/១៥១

ព្រះរាជក្រឹត្យ
ស្តីពី
លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០២ ។ល។

គ្រាស់បន្ទាប់

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ ក ដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

មាត្រា ២.-

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ប្រមូលផ្តុំមន្ត្រីបច្ចេកទេសកិរិតឧត្តម បំរើការងារបច្ចេកទេសតាមជំនាញផ្សេងៗ នៅក្នុងក្រសួង ស្ថាប័នរដ្ឋ ។

មាត្រា ៣.-

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ របស់ក្រសួងស្ថាប័នសាមីនីមួយៗ និងក្រោមការគ្រប់គ្រងរួមរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ មានឧបនិស្ស័យសំរាប់កាន់តំណែងដឹកនាំគ្រប់គ្រង សិក្សាស្រាវជ្រាវ លើកយោបល់ ធ្វើអធិការកិច្ចនិងទទួលខុសត្រូវ លើការងារបច្ចេកទេសក្នុងអង្គភាពបច្ចេកទេសជំនាញនៅថ្នាក់កណ្តាល និងខេត្ត ក្រុង និងតាមគ្រឹះស្ថានសាធារណៈនានារបស់ក្រសួង ស្ថាប័នរដ្ឋ ។

ជំពូកទី ២

ឋានន្តរស័ក្តិ និងមុខតំណែង

មាត្រា ៤.-

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់មាន ៣ ឋានន្តរស័ក្តិ :

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែពិសេសមាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែមាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់មាន ១៤ ថ្នាក់ ។ល។

មាត្រា ៥.-

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ អាចកាន់មុខតំណែងដឹកនាំគ្រប់គ្រង រួមជាមួយនិងមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅតាមអង្គភាពបច្ចេកទេសជំនាញនានា របស់ក្រសួង ស្ថាប័ននៅថ្នាក់កណ្ដាល និង ខេត្ត ក្រុង និងតាមគ្រឹះស្ថានសាធារណៈ ដូចតទៅ :

• ឋានន្តរស័ក្តិទី ១ :
  - អគ្គលេខាធិការ
  - អគ្គនាយក អគ្គាធិការ
• ឋានន្តរស័ក្តិទី ២ :
  - អគ្គលេខាធិការរង
  - អគ្គនាយករង អគ្គាធិការរង
  - ប្រធាននាយកដ្ឋាន អធិការ
• ឋានន្តរស័ក្តិទី ៣ :
  - អធិការរង
  - អនុប្រធាននាយកដ្ឋាន
  - ប្រធានមន្ទីរខេត្ត ក្រុង

និងមុខតំណែងឯទៀត ដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ក្នុងឋានន្តរស័ក្តិនីមួយៗ ក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

ជំពូកទី ៣
ការជ្រើសរើស

មាត្រា ៦.-

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើសក្នុងចំណោមបេក្ខជនជានិស្សិត និងជាមន្ត្រីរាជការ ។

ចំនួនមុខតំណែងជ្រើសរើសតាមជំនាញ និងតាមក្រសួង ស្ថាប័ន ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដោយយោងតាមការស្នើសុំពីក្រសួង ស្ថាប័នសាមី ។

មាត្រា ៧.-

ការប្រលងជ្រើសរើសក្នុងចំណោមនិស្សិត ត្រូវបើកចំហចំពោះបេក្ខជន ដែលមានអាយុច្រើនបំផុត ៣០ ឆ្នាំ គិតមកដល់ថ្ងៃប្រលង និងយ៉ាងទាបមានសញ្ញាប័ត្រវិស្វករ បរិញ្ញាបត្រ ឬសញ្ញាប័ត្រសមមូល ។ល។

លក្ខខណ្ឌក្នុងការប្រលងចូលក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ សំរាប់បេក្ខជនជាមន្ត្រីរាជការ ត្រូវកំណត់យ៉ាងទាបត្រឹមថ្នាក់លេខ ១១ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម និងមានអាយុយ៉ាងច្រើន ៤៥ ឆ្នាំ ។ មន្ត្រីរាជការ ដែលមានសញ្ញាប័ត្រដូចកំណត់ខាងលើ មិនតម្រូវលក្ខខណ្ឌក្របខ័ណ្ឌឡើយ ។

ជំពូកទី ៤
ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និងការតាំងស៊ប់

មាត្រា ៨._

បេក្ខជនដែលបានជ្រើសរើសចូលក្របខ័ណ្ឌ តាមរយៈការប្រលងជ្រើសរើសក្នុងចំណោមនិស្សិត និងក្នុងចំណោមមន្ត្រីរាជការ ត្រូវទទួលការបណ្តុះបណ្តាលដំបូងរៀបចំដោយក្រសួង ស្ថាប័នសាមី ហើយមានឋានៈជានិស្សិត មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ។

ការបណ្តុះបណ្តាលដំបូង អាចប្រព្រឹត្តទៅតាមលក្ខណៈប្រមូលផ្តុំ ឬតាមការកំណត់ណាមួយផ្សេងទៀតរបស់រាជរដ្ឋាភិបាល ។

មាត្រា ៩._

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង និស្សិតមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដែលប្រលងជាប់ត្រូវបានបែងចែកអោយទៅបំរើការ នៅតាមអង្គភាពបច្ចេកទេសជំនាញ នៅខេត្ត ក្រុង និងថ្នាក់កណ្តាលរបស់ក្រសួង ស្ថាប័នសាមី ដោយផ្អែកលើលទ្ធផលនៃការបញ្ចប់វគ្គបណ្តុះបណ្តាល និងទៅតាមជំនាញដែលបានជ្រើសរើស ក្នុងពេលប្រលងចូល ហើយត្រូវបានតែងតាំងជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់កម្មសិក្សា ដោយប្រកាសរបស់ប្រធានស្ថាប័នទទួលបន្ទុក ដោយមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ១០._

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដែលជ្រើសរើសចេញពីនិស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ ខែ ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតែងតាំងស៊ប់ក្នុងថ្នាក់ លេខ ១៤ នៃឋានន្តរស័ក្តិទី ៣ ។

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដែលជ្រើសរើសចេញពីមន្ត្រីបច្ចេកទេសមធ្យម ពុំចាំបាច់ធ្វើកម្មសិក្សាសាកល្បងឡើយ ។ ក្រោយពីបានទទួលការបណ្តុះបណ្តាលដំបូង មន្ត្រីទាំងនេះ ត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី៣ ក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់ បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់មន្ត្រីសាមី ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។ល។

មាត្រា ១១.-

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដែលធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការងារ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅឆ្នាំទី២ទៀត ។ ក្នុងករណីធ្លាក់នៅឆ្នាំទី២នេះ កម្មសិក្សាការីដែលជ្រើសរើសពីនិស្សិត ត្រូវលុបឈ្មោះចេញ។

ជំពូកទី ៥
ការតែងតាំង

មាត្រា ១២.-

ក្រោយពេលតែងតាំងស៊ប់ក្នុងក្របខ័ណ្ឌ មន្ត្រីបច្ចេកទេសជាន់ខ្ពស់អាចត្រូវតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដែលមានកំណត់ក្នុងមាត្រា ៣ និង មាត្រា៥ ខាងលើស្របតាមឋានន្តរស័ក្តិរបស់ខ្លួន តាមបែបបទដូចមានកំណត់ក្នុង មាត្រា ១៤ និងមាត្រាបន្តបន្ទាប់នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

ជំពូកទី ៦
ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម

មាត្រា ១៣.-

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ អាចត្រូវដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬក្រៅតំណែង ដើម្បីទៅបំរើការនៅក្រសួង ស្ថាប័ន ឬអង្គភាពណាមួយផ្សេង តាមតំរូវការ និងតាមការយល់ព្រមពីសាមីខ្លួន ។

ជំពូកទី ៧
ការដំឡើងថ្នាក់ និងដំឡើងឋានន្តរស័ក្តិ

មាត្រា ១៤.-

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ត្រូវដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិជាមូលដ្ឋានសំរាប់ពិនិត្យដំឡើងថ្នាក់ មានដូចខាងក្រោម :

- គំនិតផ្តួចផ្តើមច្នៃប្រឌិត និងលទ្ធផលនៃការងារ
- ស្មារតីទទួលខុសត្រូវក្នុងការងារនិងមនសិការវិជ្ជាជីវៈ
- ការយកចិត្តទុកដាក់ចំពោះផលប្រយោជន៍ជាតិ ។ល។

- ប្រសិទ្ធភាព នៃការដឹកនាំគ្រប់គ្រងចាត់ចែងអនុវត្តការងារ

- សាមគ្គីធម៌ និងសីលធម៌រស់នៅល្អ ។

ការដំឡើងថ្នាក់មន្ត្រីរាជការ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង១ ភាគ ៤ តាមវេនអតីតភាព ។

ការដំឡើងថ្នាក់ ក្នុងឋានន្តរស័ក្តិទី ១ ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

ការដំឡើងថ្នាក់ ក្នុងឋានន្តរស័ក្តិទី ២ ត្រូវសំរេចដោយអនុក្រឹត្យ ។

ការដំឡើងថ្នាក់ ក្នុងឋានន្តរស័ក្តិទី ៣ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

មាត្រា ១៥._

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតាត្រូវដំឡើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ត្រូវដំឡើងទៅក្នុងថ្នាក់ ដែលមានសន្ទស្សន៍បៀវត្សខ្ពស់ បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់មន្ត្រីសាមី ។

ចំនួនមុខតំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ដូចតទៅ :

- ៥ % ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី១
- ២៥% ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី២
- ៧០ % ឡើងទៅសំរាប់ឋានន្តរស័ក្តិទី ៣ ។

ការដំឡើងឋានន្តរស័ក្តិ ត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋានន្តរស័ក្តិ និងតាមការវាយតម្លៃរបស់ឋានានុក្រមគ្រប់គ្រង ឬ តាមរយៈការបណ្តុះបណ្តាលរយៈពេលវែងក្នុង ឬ ក្រៅប្រទេស ។

ការដំឡើងឋានន្តរស័ក្តិទី ៣ ទៅទី ២ ត្រូវសំរេចដោយអនុក្រឹត្យ ។

ការដំឡើងឋានន្តរស័ក្តិទី ២ ទៅទី ១ ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

មាត្រា ១៦._

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី២ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិទី៣ ។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី ១ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់ទី ៧ នៃឋានន្តរស័ក្តិទី ២ ។

មាត្រា ១៧._

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនិមួយៗ នៃក្របខ័ណ្ឌនិងតម្លៃឯកតានៃសន្ទស្សន៍ត្រូវកំណត់ស្របតាមមាត្រា ៣ និងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ថាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការ ។៚

ជំពូកទី ៨
បទប្បញ្ញត្តិដោយឡែក

មាត្រា ១៨.-

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៦០ឆ្នាំ។

ការដាក់អោយចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិទី ១ ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

ការដាក់អោយចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិទី ២ ត្រូវសំរេចដោយអនុក្រឹត្យ ។

ការដាក់អោយចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិទី ៣ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

មាត្រា ១៩.-

មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដែលក្រសួង ស្ថាប័ន ចាត់អោយទៅទទួលការបំប៉ន ឬ កសបណ្តុះបណ្តាលជំនាញបន្ត ដែលមានរយៈពេលសរុបចាប់ពី ០១ ឆ្នាំ ឡើងទៅដោយមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សា ត្រូវទទួលការដំឡើងថ្នាក់ ០១ ថ្នាក់ ជាស្វ័យប្រវត្តិតាមវេនជ្រើសរើស ។

មន្ត្រីដែលមានសញ្ញាប័ត្រខ្ពស់ជាងសញ្ញាប័ត្រវិស្វករ ត្រូវដំឡើងថ្នាក់ ០១ ថ្នាក់ជាស្វ័យប្រវត្តិ ។

មាត្រា ២០.-

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ត្រូវទទួលប្រាក់បំណាច់មុខងារ ប្រាក់ហានិភ័យ និងប្រាក់បំណាច់ផ្សេងៗទៀត ស្របតាមការកំណត់នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់ បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ ។

មាត្រា ២១.-

សញ្ញាស័ក្តិ និងឯកសណ្ឋានសំរាប់មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ត្រូវកំណត់ដោយព្រះរាជក្រឹត្យមួយដោយឡែក ។

ជំពូកទី ៩
អន្តរប្បញ្ញត្តិ

មាត្រា ២២.-

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ត្រូវកសាងចេញពីការធ្វើសមាហរណកម្មមន្ត្រីរាជការដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌតាមជំនាញផ្សេងៗ នៅតាមអង្គភាពបច្ចេកទេសជំនាញថ្នាក់កណ្តាល និងខេត្តក្រុងរបស់ក្រសួង ស្ថាប័ន។ល។

ជំពូកទី ១០

អវសានប្បញ្ញត្តិ

មាត្រា ២៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ២៤.-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ២៥.-

ព្រះរាជក្រឹត្យនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ ២០០២

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នស/រកត.០៦០២.០០១៦១ **នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ : ១៣៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាខឹ តាន់

នស/រកត/០៦០២/១៥២

ព្រះរាជក្រឹត្យ

ស្តីពី

លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្ស មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ កាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០២ ។.

គ្រាស់បន្ទាប់

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា១.–

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ ខ ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

មាត្រា ២.–

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ប្រមូលផ្តុំមន្ត្រីបច្ចេកទេសកំរិតមធ្យម បំរើការងារបច្ចេកទេសតាមជំនាញផ្សេងៗ នៅក្នុងក្រសួង ស្ថាប័នរដ្ឋ ។

មាត្រា ៣.–

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង ស្ថាប័នសាមីនីមួយៗ និងក្រោមការគ្រប់គ្រងរួមរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម មានឧបនិស្ស័យសំរាប់ជាជំនួយ ដល់មន្ត្រីបច្ចេកទេសជាន់ខ្ពស់ក្នុងការសំរេច និង អនុវត្តការងារ និងអាចបំពេញមុខតំណែងដឹកនាំកំរិតមធ្យម ក្នុងអង្គភាពបច្ចេកទេសជំនាញនៅថ្នាក់កណ្តាល និងខេត្ត ក្រុង និងតាមគ្រឹះស្ថានសាធារណៈនានា របស់ក្រសួង ស្ថាប័នរដ្ឋ ។

ជំពូកទី ២

ឋានន្តរស័ក្តិ និងមុខតំណែង

មាត្រា ៤.–

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យមមាន ៣ ឋានន្តរស័ក្តិ :

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម ដើមខ្សែពិសេស មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម ដើមខ្សែ មាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យម មាន ១៤ ថ្នាក់ ។៚

មាត្រា ៥.–

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម អាចកាន់មុខតំណែងគ្រប់គ្រង រួមជាមួយនឹងមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅតាមអង្គភាពជំនាញបច្ចេកទេសនានា របស់ក្រសួង ស្ថាប័ននៅថ្នាក់កណ្ដាល និង ខេត្ត ក្រុង ដូចតទៅ :

• ឋានន្តរស័ក្តិទី ១ :
  - ប្រធានការិយាល័យនៅរដ្ឋបាលកណ្ដាល
  - អនុប្រធានមន្ទីរខេត្ត ក្រុង
• ឋានន្តរស័ក្តិទី ២ :
  - អនុប្រធានការិយាល័យនៅរដ្ឋបាលកណ្ដាល
  - ប្រធានការិយាល័យមន្ទីរខេត្ត ក្រុង
• ឋានន្តរស័ក្តិទី ៣ :
  - អនុប្រធានការិយាល័យមន្ទីរខេត្ត ក្រុង
  - ប្រធានការិយាល័យស្រុក ខ័ណ្ឌ

និងមុខតំណែងឯទៀត ដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ក្នុងឋានន្តរស័ក្តិនីមួយៗ ក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ។

ជំពូកទី ៣
ការជ្រើសរើស

មាត្រា ៦.–

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើសក្នុងចំណោមបេក្ខជនជានិស្សិត និងជាមន្ត្រីរាជការ ។

ចំនួនមុខតំណែងជ្រើសរើសតាមជំនាញ និងតាមក្រសួង ស្ថាប័ន ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដោយយោងតាមការស្នើសុំពីក្រសួង ស្ថាប័នសាមី ។

មាត្រា ៧.–

ការប្រលងជ្រើសរើសក្នុងចំណោមនិស្សិត ត្រូវបើកចំហចំពោះបេក្ខជន ដែលមានអាយុច្រើនបំផុត ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រលង និងយ៉ាងទាប មានសញ្ញាប័ត្រមធ្យមបច្ចេកទេស ឬសញ្ញាប័ត្រសមមូល ។

លក្ខខណ្ឌក្នុងការប្រលងចូលក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម សំរាប់បេក្ខជនជាមន្ត្រីរាជការ ត្រូវកំណត់យ៉ាងទាបត្រឹមថ្នាក់លេខ ១១ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម និងមានអាយុយ៉ាងច្រើន ៤០ ឆ្នាំ ។ មន្ត្រីរាជការដែលមានសញ្ញាប័ត្រដូចកំណត់ខាងលើមិនតម្រូវលក្ខខណ្ឌក្របខ័ណ្ឌឡើយ ។ ល.ក.

ជំពូកទី ៤
ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និងការតាំងស៊ប់

មាត្រា ៨.–

បេក្ខជនដែលបានជ្រើសរើសចូលក្របខ័ណ្ឌ តាមរយៈការប្រលងជ្រើសរើសក្នុងចំណោមនិស្សិត និងក្នុងចំណោមមន្ត្រីរាជការ ត្រូវទទួលការបណ្តុះបណ្តាលដំបូងរៀបចំដោយក្រសួង ស្ថាប័នសាមី ហើយមានឋានៈជានិស្សិតមន្ត្រីបច្ចេកទេសមធ្យម ។

ការបណ្តុះបណ្តាលដំបូង អាចប្រព្រឹត្តទៅតាមលក្ខណៈប្រមូលផ្តុំ ឬតាមការកំណត់ណាមួយផ្សេងទៀតរបស់រាជរដ្ឋាភិបាល ។

មាត្រា ៩.–

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង និស្សិតមន្ត្រីបច្ចេកទេសមធ្យម ដែលប្រលងជាប់ ត្រូវបានបែងចែកទៅបំរើការនៅតាមអង្គភាពបច្ចេកទេសជំនាញ នៅខេត្ត ក្រុង និងថ្នាក់កណ្តាលរបស់ក្រសួង ស្ថាប័នសាមី ដោយផ្អែកលើលទ្ធផលនៃការបញ្ចប់វគ្គបណ្តុះបណ្តាល និងទៅតាមជំនាញ ដែលបានជ្រើសរើសក្នុងពេលប្រលងចូល ហើយត្រូវបានតែងតាំងជាមន្ត្រីបច្ចេកទេសមធ្យមកម្មសិក្សា ដោយប្រកាសរបស់ប្រធានស្ថាប័នទទួលបន្ទុក ដោយមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋាមុខងារសាធារណៈ ។

មាត្រា ១០.–

មន្ត្រីបច្ចេកទេសមធ្យម ដែលជ្រើសរើសចេញពីនិស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ ខែ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតែងតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិទី៣ ។

មន្ត្រីបច្ចេកទេសមធ្យម ដែលជ្រើសរើសចេញពីមន្ត្រីបច្ចេកទេសបឋម ពុំចាំបាច់ធ្វើកម្មសិក្សាសាកល្បងឡើយ ។ ក្រោយពីបានទទួលការបណ្តុះបណ្តាលដំបូង មន្ត្រីទាំងនេះត្រូវតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ ក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់មន្ត្រីសាមី ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យមត្រូវសំរេចដោយអនុក្រឹត្យ ។

មាត្រា ១១.–

មន្ត្រីបច្ចេកទេសមធ្យម ដែលធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការងារ ត្រូវបានអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅឆ្នាំទី២ទៀត ។ ក្នុងករណីធ្លាក់នៅឆ្នាំទី២ នេះ កម្មសិក្សាការីដែលជ្រើសរើសពីនិស្សិត ត្រូវលុបឈ្មោះចេញ ។

ជំពូកទី ៥
ការតែងតាំង

មាត្រា ១២.-

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ មន្ត្រីបច្ចេកទេសមធ្យមអាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដែលមានកំណត់ក្នុងមាត្រា ៣ និង មាត្រា៥ ខាងលើស្របតាមឋានន្តរស័ក្តិរបស់ខ្លួន តាមបែបបទ ដូចមានកំណត់ក្នុងមាត្រា ២៨ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

ជំពូកទី ៦
ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម

មាត្រា ១៣.-

មន្ត្រីបច្ចេកទេសមធ្យមអាចត្រូវដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬក្រៅតំណែង ដើម្បីទៅបំរើការនៅក្រសួងស្ថាប័ន ឬអង្គភាពណាមួយផ្សេង តាមតំរូវការ និងតាមការយល់ព្រមពីសាមីខ្លួន ។

ជំពូកទី ៧
ការដំឡើងថ្នាក់ និងដំឡើងឋានន្តរស័ក្តិ

មាត្រា ១៤.-

មន្ត្រីបច្ចេកទេសមធ្យម ត្រូវបានដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិជាមូលដ្ឋាន សំរាប់ការពិនិត្យដំឡើងថ្នាក់ មានដូចខាងក្រោម :

- វិន័យ និងលទ្ធផលនៃការងារ
- ស្មារតីទទួលខុសត្រូវក្នុងការងារ និងមនសិការវិជ្ជាជីវៈ
- សាមគ្គីធម៌ និងសីលធម៌រស់នៅល្អ ។

ការដំឡើងថ្នាក់មន្ត្រីរាជការ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង១ ភាគ ៤ តាមវេនអតីតភាព ។

ការដំឡើងថ្នាក់ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។ល។

មាត្រា ១៥._

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតា ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់ លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវដំឡើងទៅក្នុងថ្នាក់ ដែលមានសន្ទស្សន៍ខ្ពស់ បន្ទាប់ពីសន្ទស្សន៍ចាស់ របស់មន្ត្រីសាមី ។

ចំនួនមុខតំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ដូចតទៅ :

- ៥ % ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី១

- ២៥% ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី២

- ៧០ % ឡើងទៅសំរាប់ឋានន្តរស័ក្តិទី ៣ ។

ការដំឡើងឋានន្តរស័ក្តិត្រូវធ្វើតាមរយៈការចុះឈ្មោះ ក្នុងតារាងតំលើងឋានន្តរស័ក្តិ និងតាមការវាយតំលៃ របស់ឋានានុក្រមគ្រប់គ្រង ឬ តាមរយៈការបណ្តុះបណ្តាល រយៈពេលវែងក្នុង ឬ ក្រៅប្រទេស ។

ការដំឡើងឋានន្តរស័ក្តិ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

មាត្រា ១៦._

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី២ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិទី៣ ។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី ១ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់ទី ៧ នៃឋានន្តរស័ក្តិទី ២ ។

មាត្រា ១៧._

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌនិងតម្លៃឯកតានៃសន្ទស្សន៍ ត្រូវកំណត់ស្របតាម មាត្រា ៣ និងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្ស មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការ ។

ជំពូកទី ៨
បទប្បញ្ញត្តិដោយឡែក

មាត្រា ១៨._

មន្ត្រីបច្ចេកទេសមធ្យមត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៥៨ ឆ្នាំ ។

ការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។ ៚

មាត្រា ១៩.-

មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដែលក្រសួង ស្ថាប័ន ចាត់អោយទៅទទួលការបំប៉ន ឬការបណ្តុះបណ្តាលជំនាញបន្ត ដែលមានរយៈពេលសរុបចាប់ពី ០១ ឆ្នាំ ឡើងទៅដោយមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សា ត្រូវបានទទួលការដំឡើងថ្នាក់ ០១ ថ្នាក់ ជាស្វ័យប្រវត្តិតាមវេនជ្រើសរើស ។

មន្ត្រីដែលមានសញ្ញាប័ត្រខ្ពស់ជាងសញ្ញាប័ត្រមធ្យមបច្ចេកទេស ត្រូវបានដំឡើងថ្នាក់ ០១ ថ្នាក់ជាស្វ័យប្រវត្តិ ។

មាត្រា ២០.-

មន្ត្រីបច្ចេកទេសមធ្យម ត្រូវបានទទួលប្រាក់បំណាច់មុខងារ ប្រាក់ហានិភ័យ និងប្រាក់បំណាច់ផ្សេងៗស្របតាមការកំណត់នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់ បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ ។

មាត្រា ២១.-

សញ្ញាស័ក្តិ និងឯកសណ្ឋានសំរាប់មន្ត្រីបច្ចេកទេសមធ្យម ត្រូវកំណត់ដោយព្រះរាជក្រឹត្យមួយដោយឡែក ។

ជំពូកទី ៩
អន្តរប្បញ្ញត្តិ

មាត្រា ២២.-

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ត្រូវកសាងចេញពីការធ្វើសមាហរណកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌ តាមជំនាញផ្សេងៗ នៅតាមអង្គភាពបច្ចេកទេសជំនាញ ថ្នាក់កណ្តាល និងខេត្ត ក្រុងរបស់ក្រសួង ស្ថាប័ន។

ជំពូកទី ១០
អវសានប្បញ្ញត្តិ

មាត្រា ២៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៤.-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យ នេះ ។/.

មាត្រា ២៥.–

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។ ៧ត.

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០២

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ : ១៣៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សោម គាន់

នស/រកត/០៦០២/១៥៣

ព្រះរាជក្រឹត្យ
ស្ដីពី
លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្ដីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលស្នើសុំពីសម្ដេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០២ ។ល។

គ្រាស់បន្ទាប់
ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ គ ដូចមានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

មាត្រា ២.-

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ប្រមូលផ្ដុំមន្ត្រីដែលមានទេពកោសល្យបច្ចេកទេសឬការយល់ដឹង ក្នុងការអនុវត្តជាក់ស្ដែង សំរាប់ប្រតិបត្តិការងារជំនាញផ្សេងៗ នៅក្នុងអង្គភាពបច្ចេកទេសជំនាញ នៅថ្នាក់កណ្ដាល និង ខេត្ត ក្រុង និងគ្រឹះស្ថានសាធារណៈរបស់ក្រសួង ស្ថាប័ន ។

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម មានឧបនិស្ស័យអាចបំពេញមុខតំណែងត្រួតពិនិត្យលើការងារ របស់មន្ត្រីក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេសផងដែរ ។

មាត្រា ៣.-

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ របស់ក្រសួង ស្ថាប័នសាមីនីមួយៗ និង ក្រោមការគ្រប់គ្រងរួម របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ៤.-

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋមមាន ៣ ឋានន្តរស័ក្តិ :

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសបឋម ជើមវិសេស មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសបឋម ជើមវែរ មាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសបឋម មាន ១៤ ថ្នាក់ ។ ល។

ជំពូកទី ២
ការជ្រើសរើស

មាត្រា ៥.–

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស ក្នុងចំណោមបេក្ខជនជាសិស្ស និស្សិត និងជាមន្ត្រីរាជការ ។

ចំនួនមុខតំណែងជ្រើសរើសតាមជំនាញ និងតាមក្រសួង ស្ថាប័ន ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដោយយោងតាមការស្នើសុំពីក្រសួង ស្ថាប័នសាមី ។

មាត្រា ៦.–

ការប្រលងជ្រើសរើស ក្នុងចំណោមសិស្ស និស្សិត ត្រូវបើកចំហចំពោះបេក្ខជន ដែលមានអាយុច្រើនបំផុត ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រលង និងយ៉ាងទាប មានសញ្ញាប័ត្រមធ្យមសិក្សាភាគទី ២ ឬសញ្ញាប័ត្រសមមូល ។

លក្ខខណ្ឌក្នុងការប្រលងចូលក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម សំរាប់បេក្ខជនជាមន្ត្រីរាជការ ត្រូវកំណត់យ៉ាងទាបត្រឹមថ្នាក់លេខ ១១ នៃក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ឬមានសញ្ញាប័ត្រដូចកំណត់ខាងលើ ។

ជំពូកទី ៣
កម្មសិក្សាសាកល្បង ការតាំងស៊ប់ និងការតែងតាំង

មាត្រា ៧.–

បេក្ខជនដែលប្រលងជាប់ ត្រូវបែងចែកអោយទៅបំរើការនៅតាមអង្គភាពបច្ចេកទេសជំនាញ នៅខេត្ត ក្រុង និងថ្នាក់កណ្តាល របស់ក្រសួង ស្ថាប័នសាមី ទៅតាមជំនាញ ដែលជ្រើសរើសក្នុងពេលប្រលងចូល ហើយត្រូវតែងតាំងជាមន្ត្រីបច្ចេកទេសបឋមកម្មសិក្សា ដោយប្រកាស របស់ប្រធានស្ថាប័នទទួលបន្ទុក។

មាត្រា ៨.–

មន្ត្រីបច្ចេកទេសបឋម ដែលជ្រើសរើសចេញពីសិស្ស និស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ ខែ ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតែងតាំងស៊ប់ក្នុងថ្នាក់ លេខ ១៤ នៃឋានន្តរស័ក្តិទី ៣ ។ល។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋមត្រូវសំរេចដោយប្រកាសរបស់ក្រសួងស្ថាប័នសាមី ដោយមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ៩._

មន្ត្រីបច្ចេកទេសបឋម ដែលធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំពេញការងារ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅឆ្នាំ ទី២ទៀត ។ ក្នុងករណីធ្លាក់នៅឆ្នាំទី២ នេះ កម្មសិក្សាការីដែលជ្រើសរើសពីសិស្សនិស្សិតត្រូវលុបឈ្មោះចេញ ។

មាត្រា ១០._

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម អាចត្រូវតែងតាំងក្នុងមុខតំណែងទំនេរណាមួយដែលមានកំណត់ក្នុងមាត្រា ២ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួនតាមកែវបទ ដូចមានចែងក្នុងមាត្រា ២៨ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

មាត្រា ១១._

មន្ត្រីបច្ចេកទេសបឋម អាចត្រូវដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬក្រៅតំណែង ដើម្បីទៅបំពេញការនៅក្រសួងស្ថាប័ន ឬអង្គភាពណាមួយផ្សេង តាមតំរូវការ និងតាមការយល់ព្រមពីសាមីខ្លួន ។

ជំពូកទី ៤
ការដំឡើងថ្នាក់ និងដំឡើងឋានន្តរស័ក្តិ

មាត្រា ១២._

មន្ត្រីបច្ចេកទេសបឋម ត្រូវបានដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិជាមូលដ្ឋានសំរាប់ការពិនិត្យដំឡើងថ្នាក់ មានដូចខាងក្រោម :

- វិន័យ និងលទ្ធផលការងារ
- ស្មារតីទទួលខុសត្រូវក្នុងការងារ និងមនសិការវិជ្ជាជីវៈ
  សោលធម៌ និងសីលធម៌រស់នៅល្អ ។

ការដំឡើងថ្នាក់នៃមន្ត្រីរាជការ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង១ ភាគ ៤ តាមវេនអតីតភាព ។

ការដំឡើងថ្នាក់ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។ល។

ការដំឡើងថ្នាក់នៃមន្ត្រីរាជការ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង១ ភាគ ៤ តាមវេនអតីតភាព ។

ការដំឡើងថ្នាក់ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

មាត្រា ១៣.-

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតា ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់ លើបន្ទាប់ ឬ ក្នុងករណីចាំបាច់ ត្រូវដំឡើងទៅក្នុងថ្នាក់ ដែលមានសន្ទស្សន៍បៀវត្សខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់ របស់មន្ត្រីសាមី ។

ចំនួនមុខតំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ដូចខាងក្រោម :

- ៥ % ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី១
- ២៥% ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី២
- ៧០ % ឡើងទៅសំរាប់ឋានន្តរស័ក្តិទី ៣ ។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី២ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិទី៣ ។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី ១ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់ទី ៧ នៃឋានន្តរស័ក្តិទី ២ ។

ការដំឡើងឋានន្តរស័ក្តិត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

មាត្រា ១៤.-

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌនិងតំណែងគតានៃសន្ទស្សន៍ត្រូវកំណត់ស្របតាម មាត្រា ៣ និងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការ ។

ជំពូកទី ៥
បញ្ញត្តិដោយឡែក

មាត្រា ១៥.-

មន្ត្រីបច្ចេកទេសបឋមត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៥៥ ឆ្នាំ ។

ការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។៚

ជំពូកទី ៦

អន្តរប្បញ្ញត្តិ

មាត្រា ១៦._

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ត្រូវកសាងចេញពីការជ្រើសមាហរណកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌ តាមជំនាញផ្សេងៗ នៅតាមអង្គភាពបច្ចេកទេសជំនាញថ្នាក់កណ្តាល និងខេត្តក្រុងរបស់ក្រសួង ស្ថាប័ន ។

ជំពូកទី ៧

អវសានប្បញ្ញត្តិ

មាត្រា ១៧._

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៨._

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ១៩._

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។៘.

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ ២០០២

ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ

នស/រកត/០៦០២/១៦៣ **នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្ថលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ : ១៤០ ច.ល

ដើម្បីចម្លងចែរ

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឌី តាន់

នស/រកត/០៦០២/១៥៤

ព្រះរាជក្រឹត្យ
ស្តីពី
លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស, អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០២ ។

គ្រាស់បន្ទាប់

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា១.‒

ត្រូវបានបង្កើតក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ ឃ ដូចមានចែងក្នុងមាត្រា ៦ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

មាត្រា ២.‒

ក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ប្រមូលផ្តុំមន្ត្រីដែលមានមុខងារក្នុងការប្រតិបត្តិផ្សេងៗ នៅក្នុងអង្គភាពបច្ចេកទេសជំនាញ នៅថ្នាក់កណ្តាល និងខេត្តក្រុង នៃក្រសួង ស្ថាប័ន ។

មាត្រា ៣.‒

ក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ របស់ក្រសួង ស្ថាប័នសាមីនីមួយៗ និងក្រោមការគ្រប់គ្រងរួម របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ៤.‒

ក្របខ័ណ្ឌភ្នាក់បច្ចេកទេសមាន ៣ ឋានន្តរស័ក្តិ :

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិនាយភ្នាក់ងារបច្ចេកទេស មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិភ្នាក់ងារបច្ចេកទេសដើមខ្សែ មាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិភ្នាក់ងារបច្ចេកទេស មាន ១៤ ថ្នាក់ ។

ជំពូកទី ២

ការជ្រើសរើស

មាត្រា ៥.‒

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស រៀបចំដោយក្រសួង ស្ថាប័នសាមី ។

ចំនួនមុខតំណែងជ្រើសរើស ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់មុខងារសាធារណៈ ដោយយោងតាមការស្នើសុំពីក្រសួង ស្ថាប័នសាមី ។៚

មាត្រា ៦.–

ការប្រលងជ្រើសរើស ត្រូវបើកចំហចំពោះបេក្ខជន ដែលមានកាយសម្បទាសមស្របតាមការងារ និងមានអាយុច្រើនបំផុត ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រលង ដោយពុំគូរវនូវលក្ខខណ្ឌសញ្ញាប័ត្រអ្វីឡើយ ។

ជំពូកទី ៣

កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

មាត្រា ៧.–

បេក្ខជនដែលប្រលងជាប់ ត្រូវបែងចែកអោយទៅបំរើការនៅតាមអង្គភាពបច្ចេកទេសជំនាញ នៅខេត្ត ក្រុង និងថ្នាក់កណ្តាល របស់ក្រសួង ស្ថាប័ន ហើយត្រូវបានតែងតាំងជាភ្នាក់ងារបច្ចេកទេសកម្មសិក្សាដោយប្រកាសរបស់ប្រធានស្ថាប័នទទួលបន្ទុក ។

កម្មសិក្សានេះមានរយៈពេល ១២ ខែ ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតែងតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរ ស័ក្តិទី ៣ ដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ដោយមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ៨.–

ភ្នាក់ងារបច្ចេកទេស ដែលធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការងារ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅឆ្នាំទី ២ ទៀត ។ ក្នុងករណីធ្លាក់នៅឆ្នាំទី ២នេះ ភ្នាក់ងារនោះត្រូវលុបឈ្មោះចេញ។

ជំពូកទី ៤

ការដំឡើងថ្នាក់ និងដំឡើងឋានន្តរស័ក្តិ

មាត្រា ៩.–

ភ្នាក់ងារបច្ចេកទេស ត្រូវបានដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិជាមូលដ្ឋានសំរាប់ការពិនិត្យតំលើងថ្នាក់ មានដូចខាងក្រោម :

- វិន័យ និងលទ្ធផលការងារ
- ស្មារតីទទួលខុសត្រូវក្នុងការងារ និងមនសិការវិជ្ជាជីវៈ
- សាមគ្គីធម៌ និងសីលធម៌រស់នៅល្អ ។

ការដំឡើងថ្នាក់នៃមន្ត្រីរាជការ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង១ ភាគ ៤ តាមវេនអតីតភាព ។៙ ។

ការដំឡើងថ្នាក់ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

មាត្រា ១០.-

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតា ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់ លើបន្ទាប់។

ចំនួនមុខតំណែងក្នុងឋានន្តរស័ក្តិនិមួយៗ ត្រូវកំណត់ដូចតទៅ :

- ៥ % ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី១
- ២៥% ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី២
- ៧០ % ឡើងទៅសំរាប់ឋានន្តរស័ក្តិទី ៣។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី ២ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិទី ៣ ។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី ១ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់ទី ៧ នៃឋានន្តរស័ក្តិទី ២ ។

ការដំឡើងឋានន្តរស័ក្តិត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

ជំពូកទី ៥
បៀវត្សផ្តល់ជូនដោយខ្សែ

មាត្រា ១១.-

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌ និងតំលៃឯកតានៃសន្ទស្សន៍ត្រូវកំណត់ស្របតាមមាត្រា ៣ និងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ថាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការ ។

មាត្រា ១២.-

ភ្នាក់ងារបច្ចេកទេសត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៥៥ ឆ្នាំ ។

ការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ។

ជំពូកទី ៦
អន្តរប្បញ្ញត្តិ

មាត្រា ១៣.-

ចំនួនដំបូងនៃក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ត្រូវកសាងចេញពីការជ្រើសមាបារណាកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌ នៅតាមអង្គភាពបច្ចេកទេសជំនាញ ថ្នាក់កណ្តាល និងខេត្ត ក្រុងរបស់ក្រសួង ស្ថាប័ន។ល។

ជំពូកទី ៧

អវសានប្បញ្ញត្តិ

មាត្រា ១៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៥.-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ១៦.-

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។ល.វ.

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០២

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

៣ រ.ល. ០២.០៦.០០១៦៤ **នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រសូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ : ១៤១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៦០២/១៥៥

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

ឃឃ

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : បំពាក់ មេដាយការពារជាតិ ជូននាយទាហានថ្នាក់ឧត្តមសេនីយ៍ចំនួន ០៤រូប ក្នុងមួយរូបៗមេដាយសំរិទ្ធចំនួន ០២គ្រឿង មេដាយប្រាក់ចំនួន ០២គ្រឿង និងមេដាយមាសចំនួន ០២គ្រឿង ដូចមានរាយនាមខាងក្រោម ៖

១-ឧត្តមសេនីយ៍ត្រី គីម ថុនថាន អត្តលេខ ០០៤៣៥៧ នាយករង ខុទ្ទកាល័យអគ្គបញ្ជាការ

២-ឧត្តមសេនីយ៍ត្រី ឃួន មុយឃួត អត្តលេខ ០០០៧១៦ នាយករងមជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រយោធា

៣-ឧត្តមសេនីយ៍ត្រី សួន ផល អត្តលេខ ០០០១៨២ នាយករងមីចាត់ការហិរញ្ញវត្ថុអគ្គបញ្ជាការដ្ឋាន

៤-ឧត្តមសេនីយ៍ត្រី សីវុទ្ធ ស៊ីនិត្យ អត្តលេខ ០០០៤៤៨ មេបញ្ជាការអង្គរក្ស កងពលតូចលេខ ៧០

មាត្រា២ : បំពាក់ មេដាយការពារជាតិ ជូននាយទាហានថ្នាក់វរសេនីយ៍ចំនួន ៩៩១រូប ក្នុងមួយរូបៗមេដាយសំរិទ្ធចំនួន ០១គ្រឿង មេដាយប្រាក់ចំនួន ០១គ្រឿង និងមេដាយមាសចំនួន ០១គ្រឿង ដូចមានរាយនាមខាងក្រោម ៖

១-វរសេនីយ៍ឯក នរោត្តម ចិន្តាវី អត្តលេខ ០០៤៣៧៧ ជំនួយការព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន

២-វរសេនីយ៍ឯក ថាច់ ស៊ីដេត អត្តលេខ ០០៤៣៧៥ ជំនួយការព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន

៣-វរសេនីយ៍ឯក ស៊ីសុវត្ថិ សុជាតិបុប្ផុម អត្តលេខ ០០០៥៩៤ នាយទាហាន នាយកដ្ឋានទាក់ទងអន្តរជាតិ

៤ - វរសេនីយ៍ឯក	ឆាវ	ឆាដ	អត្តលេខ	០០១៩៨៧	នាយករង នាយកដ្ឋានទាក់ទងអន្តរជាតិ
៥ - វរសេនីយ៍ឯក	មាស	ម៉ារធី	អត្តលេខ	០០១៩៦៤	នាយករង ទីចាត់ការផែនការ
៦ - វរសេនីយ៍ឯក	ស្វាយ	ថុនមុន្នី	អត្តលេខ	០០០៩១៧	នាយរងការិយាល័យទី៥ បញ្ជាការដ្ឋានកងទ័ពជើងគោក
៧ - វរសេនីយ៍ឯក	ឌី	ឌីន	អត្តលេខ	០០៤៤២៨	នាយសេនាធិការរង យោធភូមិភាគទី ១
៨ - វរសេនីយ៍ឯក	ខាន់	សឿន	អត្តលេខ	០០៤៤២៩	នាយសេនាធិការរង យោធភូមិភាគទី ២
៩ - វរសេនីយ៍ឯក	នួន	ដៅ	អត្តលេខ	០០៤៤៣០	នាយសេនាធិការរង យោធភូមិភាគទី ៤
១០ - វរសេនីយ៍ឯក	នេម	អយ	អត្តលេខ	០០៤៤៣២	នាយសេនាធិការរង យោធភូមិភាគទី ៤
១១ - វរសេនីយ៍ឯក	ហាំ	អនស្ទី	អត្តលេខ	០០៤៤៣៤	នាយសេនាធិការរង យោធភូមិភាគទី ៤
១២ - វរសេនីយ៍ឯក	ជូ	ឌិន	អត្តលេខ	០០៤៤៣៣	នាយសេនាធិការរង កងពលធំលេខ២ យោធភូមិភាគទី ៤
១៣ - វរសេនីយ៍ឯក	ឌខ	សារ៉ន	អត្តលេខ	០០៤៤៣៥	នាយសេនាធិការរង កងពលធំលេខ២ យោធភូមិភាគទី ៤
១៤ - វរសេនីយ៍ឯក	ប៉ិច	នួត	អត្តលេខ	០០៤៤៣១	មេបញ្ជាការរង កងពលតូចលេខ១៥ យោធភូមិភាគទី ៤
១៥ - វរសេនីយ៍ឯក	ចាប	ម៉ៅ	អត្តលេខ	០០៣៩៣៩	មេបញ្ជាការរង កងពលតូចលេខ១៦ យោធភូមិភាគទី ៥
១៦ - វរសេនីយ៍ឯក	ម៉ាត់	ឈឿន	អត្តលេខ	០០៣៩០៧	មេបញ្ជាការរង កងពលតូចលេខ១៦ យោធភូមិភាគទី ៥
១៧ - វរសេនីយ៍ឯក	ភ្រាំ	ប៊ិត	អត្តលេខ	០០៣៩១០	មេបញ្ជាការរង កងពលតូចលេខ១៦ យោធភូមិភាគទី ៥
១៨ - វរសេនីយ៍ឯក	ពេជ្រ	សៀត	អត្តលេខ	០០៣៩១១	មេបញ្ជាការរង កងពលតូចលេខ១៦ យោធភូមិភាគទី ៥
១៩ - វរសេនីយ៍ឯក	ស៊ូ	សម្បត្តិ	អត្តលេខ	០០៣៩១២	មេបញ្ជាការរង កងពលតូចលេខ១៦ យោធភូមិភាគទី ៥
២០ - វរសេនីយ៍ឯក	សូ	ណារ៉ា	អត្តលេខ	០០៤៤១០	មេបញ្ជាការរង កងហោះដឹកជញ្ជូនគណៈប្រតិភូ បញ្ជាការដ្ឋានកងទ័ពជើងអាកាស
២១ - វរសេនីយ៍ឯក	យត់	ទ្រឹង	អត្តលេខ	០០០៤៦៨	មេបញ្ជាការរង កងហោះដឹកជញ្ជូនគណៈប្រតិភូ បញ្ជាការដ្ឋានកងទ័ពជើងអាកាស
២២ - វរសេនីយ៍ឯក	ឆាង	និន្ទ	អត្តលេខ	០០៤៤០៨	មេបញ្ជាការរង កងហោះដឹកជញ្ជូនគណៈប្រតិភូ បញ្ជាការដ្ឋានកងទ័ពជើងអាកាស
២៣ - វរសេនីយ៍ឯក	ម៉ាញ	យ៉ារិន	អត្តលេខ	០០៤៤០៩	មេបញ្ជាការរង កងហោះដឹកជញ្ជូនគណៈប្រតិភូ បញ្ជាការដ្ឋានកងទ័ពជើងអាកាស
២៤ - វរសេនីយ៍ឯក	គឹម	សាយួន	អត្តលេខ	០០៤៥២៥	ប្រធានក្រុមហោះ AN-24 បញ្ជាការដ្ឋានកងទ័ពជើងអាកាស
២៥ - វរសេនីយ៍ឯក	ហ៊ីម	ណារិន	អត្តលេខ	០០៤៥២៤	អាកាសគោចរ AN-24 បញ្ជាការដ្ឋានកងទ័ពជើងអាកាស
២៦ - វរសេនីយ៍ទោ	ខូន	ត្រារា	អត្តលេខ	០០៨៥៨៥	នាយរងការិយាល័យបណ្ដុះបណ្ដាល នាយកដ្ឋានបុគ្គលិក
២៧ - វរសេនីយ៍ទោ	អ៊ែម	ឧត្តមច័ន្ទណារ៉ា	អត្តលេខ	០០៤៤៥៨	នាយកការិយាល័យកិច្ចការរដ្ឋបាលហិរញ្ញវត្ថុ នាយកដ្ឋាននយោបាយផែនការ
២៨ - វរសេនីយ៍ទោ	គួល	សាផាន	អត្តលេខ	០១០៩៣០	នាយកការិយាល័យបច្ចេកទេសជើងទឹក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស
២៩ - វរសេនីយ៍ទោ	ថោង	ស៊ីថា	អត្តលេខ	០១១៣៥៤	នាយរងលេខាធិការដ្ឋាន អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស
៣០ - វរសេនីយ៍ទោ	ពេញ	សុផាត	អត្តលេខ	០១៣៩១៧	នាយរងអង្គភាពសេវា អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស
៣១ - វរសេនីយ៍ទោ	ខិន	តត្តជា	អត្តលេខ	០១៩៨២៥	នាយកការិយាល័យភស្តុភារ-ហិរញ្ញវត្ថុ នាយកដ្ឋានទាក់ទងអន្តរជាតិ

៣២ - វរសេនីយ៍ទោ សំ សីហា អត្តលេខ ០១៩០២៦ នាយករង មជ្ឈមណ្ឌលយោធិនពិការ ៣១៧
៣៣ - វរសេនីយ៍ទោ សួស ចាន់ធី អត្តលេខ ០១១៩២៧ ជំនួយការ អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា
៣៤ - វរសេនីយ៍ទោ សេខ អៀ អត្តលេខ ០១៩១០៤ លេខាផ្ទាល់ អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា
៣៥ - វរសេនីយ៍ទោ សំ សំអន អត្តលេខ ០០៨៦១៤ ជំនួយការផ្ទាល់ អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា
៣៦ - វរសេនីយ៍ទោ ចាន់ សុភា អត្តលេខ ០១០៩៦៣ នាយរងលេខាធិការដ្ឋាន អគ្គនាយកដ្ឋានយោធសេវា
៣៧ - វរសេនីយ៍ទោ ឃុន ឡុងធី អត្តលេខ ០០៨៩៨៧ នាយរងលេខាធិការដ្ឋាន អគ្គនាយកដ្ឋានយោធសេវា
៣៨ - វរសេនីយ៍ទោ និត្យ ច័ន្ទបូរណីមី អត្តលេខ ០០៨៣៩៨ នាយរងការិយាល័យអ្នកនាំពាក្យ នាយកដ្ឋានព័ត៌មាន
៣៩ - វរសេនីយ៍ទោ ប៉ែន យ៉ារ៉ាន់ អត្តលេខ ០០៨៦៧២ នាយការិយាល័យហិរញ្ញវត្ថុ វិទ្យុស្ថានយោធាកម្ពុជា
៤០ - វរសេនីយ៍ទោ ជុំ សារ៉ាត់ អត្តលេខ ០០១៩៤៤ នាយករងមជ្ឈមណ្ឌលហ្វឹកហ្វឺនភាសាបរទេស វិទ្យាស្ថានយោធាកម្ពុជា
៤១ - វរសេនីយ៍ទោ គី ម៉ាលី អត្តលេខ ០០៩០២៦ លេខាផ្ទាល់ឯកឧត្តម គន់ គីម
៤២ - វរសេនីយ៍ទោ សូ សារឿន អត្តលេខ ០០៥២៩១ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងខេត្តកណ្តាល
៤៣ - វរសេនីយ៍ទោ ញឹម សារីម អត្តលេខ ០០៥២៩២ នាយរងផ្នែកហិរញ្ញវត្ថុ ខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន
៤៤ - វរសេនីយ៍ទោ និត្យ សុចណ្ណតារា អត្តលេខ ០១៩១៩៥ នាយរងការិយាល័យបច្ចេកទេស នាយកដ្ឋានវិស្វកម្ម
៤៥ - វរសេនីយ៍ទោ ហួរ សៀវលីម អត្តលេខ ០០៣.២៤៨ ជំនួយការឯកឧត្តម ទួខ ស៊ីផាន
៤៦ - វរសេនីយ៍ទោ អ៊ូ សុធី អត្តលេខ ០០៩.១៣៩ នាយរងការិយាល័យវិន័យ-ទណ្ឌកម្ម ទីចាត់ការបុគ្គលិក
៤៧ - វរសេនីយ៍ទោ ខៀវ ឆេន អត្តលេខ ០០៨.៧១០ នាយរងការិយាល័យបំរុង-រំសាយ ទីចាត់ការបុគ្គលិក
៤៨ - វរសេនីយ៍ទោ ពៅ ផាន្លី អត្តលេខ ០០១.១៣៦ នាយទាហានរង់ចាំ ទីចាត់ការបុគ្គលិក
៤៩ - វរសេនីយ៍ទោ តែង សុចណ្ណរិទ្ធ អត្តលេខ ០០២.៣១៧ នាយទាហានរង់ចាំ ទីចាត់ការបុគ្គលិក
៥០ - វរសេនីយ៍ទោ រ៉ាំខ ច័ន្ទលក្ខិណា អត្តលេខ ០០៣.០៩០ នាយទាហានរង់ចាំ ទីចាត់ការបុគ្គលិក
៥១ - វរសេនីយ៍ទោ ធឿន យ៉ុន អត្តលេខ ០០១.០៧៩ នាយទាហានរង់ចាំ ទីចាត់ការបុគ្គលិក
៥២ - វរសេនីយ៍ទោ មាស សារឿន អត្តលេខ ០០២.៩៦៧ នាយទាហានរង់ចាំ ទីចាត់ការបុគ្គលិក
៥៣ - វរសេនីយ៍ទោ គឹម សុន្ទរ៉ា អត្តលេខ ០០៤.៩០៣ នាយរងការិយាល័យកិច្ចការស៊ីវិល ទីចាត់ការឃោសនាព័ត៌មាន
៥៤ - វរសេនីយ៍ទោ ធឹម សុចណ្ណ អត្តលេខ ០០៩.០៦៥ នាយការិយាល័យបុគ្គលិក បញ្ជាការដ្ឋានបញ្ជូនសារ
៥៥ - វរសេនីយ៍ទោ ស សារិទ្ធ អត្តលេខ ០០៩.០៧៦ នាយផ្នែកហិរញ្ញវត្ថុ បញ្ជាការដ្ឋានបញ្ជូនសារ
៥៦ - វរសេនីយ៍ទោ ធឹម សារៈ អត្តលេខ ០០២.១៣០ នាយរងការិយាល័យការពារគីមីសាស្ត្រ ទីចាត់ការគីមីសាស្ត្រ
៥៧ - វរសេនីយ៍ទោ ព្រុំ ថារី អត្តលេខ ០០០.៨៤៨ នាយផ្នែកមុខវិជ្ជាគ្រូការពារអាកាស សាលានាយទាហានចំរុះ
៥៨ - វរសេនីយ៍ទោ សាន ជាតិមប៉ូ អត្តលេខ ០០៤.៨៥០ នាយរងការិយាល័យស្ថាប័នចំណុះ អធិការដ្ឋាន
៥៩ - វរសេនីយ៍ទោ ស៊ុន លីន អត្តលេខ ០០២.៣០៤ ជំនួយការ ទីចាត់ការការពារព្រំដែន
៦០ - វរសេនីយ៍ទោ ពេជ្រ មុន្នី អត្តលេខ ០០២.១៨០ នាយរងការិយាល័យព្រំដែនវៀតណាម ទីចាត់ការការពារព្រំដែន
៦១ - វរសេនីយ៍ទោ រួន រ័ត្នខាសនា អត្តលេខ ០១២.៧៤៤ មេបញ្ជាការរង កងរាជអាវុធហត្ថខេត្តកំពង់ឆ្នាំង
៦២ - វរសេនីយ៍ទោ ដួ ឃីន អត្តលេខ ០១២.០៩១ មេបញ្ជាការរង-កងរាជអាវុធហត្ថខេត្តកោះកុង
៦៣ - វរសេនីយ៍ទោ ញាណ សារុំ អត្តលេខ ០០១.០១០ នាយរងការិយាល័យដឹកជញ្ជូន ទីចាត់ការចលនូបត្ថម្ភ

៦៤ -	វរសេនីយ៍ទោ	ជិន	គិត	អត្តលេខ ០១១.៨០៦	នាយសេនាធិការរង កងពលតូចឆត្រយោង ៩១១
៦៥ -	វរសេនីយ៍ទោ	សុយ	សារម៉េត	អត្តលេខ ០០៣.២៣៨	នាយរងផ្នែកបូកសរុបការិយាល័យទី ៣ បញ្ជាការដ្ឋានកងទ័ពជើងគោក
៦៦ -	វរសេនីយ៍ទោ	ប៊ិច	ខ្ឡូន	អត្តលេខ ០០០.៨៨៨	មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងមណ្ឌលគិរី យោធភូមិភាគទី ១
៦៧ -	វរសេនីយ៍ទោ	សឿន	សារឿត	អត្តលេខ ០០០.៨៨៦	មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងមណ្ឌលគិរី យោធភូមិភាគទី ១
៦៨ -	វរសេនីយ៍ទោ	សួ	ចំរើន	អត្តលេខ ០០០.៨៨៩	មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងមណ្ឌលគិរី យោធភូមិភាគទី ១
៦៩ -	វរសេនីយ៍ទោ	ជិន	សារឿន	អត្តលេខ ០០៤.៥៣០	មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងមណ្ឌលគិរី យោធភូមិភាគទី ១
៧០ -	វរសេនីយ៍ទោ	អួម	ឃួម	អត្តលេខ ០០០.៨៧៩	មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងមណ្ឌលគិរី យោធភូមិភាគទី ១
៧១ -	វរសេនីយ៍ទោ	ម៉ៅ	ផាទី	អត្តលេខ ០០៤.១១១	មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងក្រចេះ យោធភូមិភាគទី ២
៧២ -	វរសេនីយ៍ទោ	សម	ញាណ	អត្តលេខ ០០៤.៥៣៣	មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងក្រចេះ យោធភូមិភាគទី ២
៧៣ -	វរសេនីយ៍ទោ	នួន	ហេង	អត្តលេខ ០០០.៨៩៩	មេបញ្ជាការរងនិងជានាយសេនាធិការតំបន់ប្រតិបត្តិការសឹករងព្រៃវែង យោធភូមិភាគទី ២
៧៤ -	វរសេនីយ៍ទោ	ថាច់	ចណ្ណារិទ្ធ	អត្តលេខ ០០០.៧២៥	នាយរងការិយាល័យយោធាតំបន់ យោធភូមិភាគទី ២
៧៥ -	វរសេនីយ៍ទោ	ញ៉ឹត	ប៊ុនឈី	អត្តលេខ ០០៤.៩៧៩	មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងក្រុងកែប យោធភូមិភាគទី ៣
៧៦ -	វរសេនីយ៍ទោ	ប៊ុន	ថូ	អត្តលេខ ០០៥.០២៤	មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងកោះកុង យោធភូមិភាគទី ៣
៧៧ -	វរសេនីយ៍ទោ	នៅ	ឡឿន	អត្តលេខ ០០០.៩៤៦	នាយទាហានរង់ចាំ យោធភូមិភាគទី ៣
៧៨ -	វរសេនីយ៍ទោ	ធឿង	ធា	អត្តលេខ ០០៩.៩៨៦	មេបញ្ជាការរង កងពលតូចលេខ ៣ យោធភូមិភាគទី ៤
៧៩ -	វរសេនីយ៍ទោ	ជាតិ	ប៉ុច	អត្តលេខ ០០០.៩៩៣	មេបញ្ជាការរង កងពលតូចលេខ ៣ យោធភូមិភាគទី ៤
៨០ -	វរសេនីយ៍ទោ	ឈុត	រឿន	អត្តលេខ ០១០.១៥៥	មេបញ្ជាការរងនិងជានាយសេនាធិការ កងពលតូច លេខ ៣ យោធភូមិភាគទី ៤
៨១ -	វរសេនីយ៍ទោ	ឈឹន	នី	អត្តលេខ ០០០.៩៩៩	មេបញ្ជាការរងកងពលតូចលេខ ៧២ យោធភូមិភាគទី ៤
៨២ -	វរសេនីយ៍ទោ	ប៊ុន	ម៉ន	អត្តលេខ ០០១.២៩៧	នាយសេនាធិការរង កងពលធំលេខ២០ យោធភូមិភាគទី ៤
៨៣ -	វរសេនីយ៍ទោ	ជា	ស៊ី	អត្តលេខ ០០១.១២០	នាយសេនាធិការរងកងពលតូចអន្តរាគមន៍ ១៤ បញ្ជាការដ្ឋានកងទ័ពជើងគោក
៨៤ -	វរសេនីយ៍ទោ	សេដ្ឋ	សំអុល	អត្តលេខ ០០៣.៦១៥	នាយសេនាធិការរងកងពលតូចអន្តរាគមន៍ ១៤ បញ្ជាការដ្ឋានកងទ័ពជើងគោក
៨៥ -	វរសេនីយ៍ទោ	គួយ	សាឡាត់	អត្តលេខ ០០១.២៨៦	នាយសេនាធិការរងកងពលតូចអន្តរាគមន៍ ១៤ បញ្ជាការដ្ឋានកងទ័ពជើងគោក
៨៦ -	វរសេនីយ៍ទោ	ព្រំ	ឆ៊ុន	អត្តលេខ ០០១.៣០៩	មេបញ្ជាការរងកងការពារព្រំដែន ៥០១ យោធភូមិភាគទី ៥
៨៧ -	វរសេនីយ៍ទោ	អឿម	ធុំ	អត្តលេខ ០០១.៣១០	នាយទាហានរង់ចាំ កងពលតូចអន្តរាគមន៍ ១៤ យោធភូមិភាគទី ៥
៨៨ -	វរសេនីយ៍ទោ	គង់	ស៊ឹម	អត្តលេខ ០០១.៣១១	នាយទាហានរង់ចាំ កងពលតូចអន្តរាគមន៍ ១៤ យោធភូមិភាគទី ៥
៨៩ -	វរសេនីយ៍ទោ	ឆង់	ប៊ុនលី	អត្តលេខ ០០១.២៩៤	នាយរងសេនាធិការ កងពលតូចលេខ១៩ យោធភូមិភាគទី ៥
៩០ -	វរសេនីយ៍ទោ	ញៀម	សឿន	អត្តលេខ ០០៣.៩៥៣	មេបញ្ជាការ វរសេនាតូច ១៦១ កងពលតូចលេខ ១៦ យោធភូមិភាគទី ៥

៩១ - វរសេនីយ៍ទោ សួន ភឿន អត្តលេខ ០០១.២៧២ នាយសេនាធិការរង កងពលតូចលេខ ១៦ យោធភូមិភាគទី ៥
៩២ - វរសេនីយ៍ទោ សូ សារុន អត្តលេខ ០០៤.៥២៧ អាកាសគោចរ AN-24 បញ្ជាការដ្ឋានកងទ័ពជើងអាកាស
៩៣ - វរសេនីយ៍ទោ គាត់ . ភន្ទុល អត្តលេខ ០០៤.៥២៣ នាយការិយាល័យរដ្ឋបាល បញ្ជាការដ្ឋានកងទ័ពជើងអាកាស
៩៤ - វរសេនីយ៍ទោ ម៉េង · គីម អត្តលេខ ០០៤.៥២៨ វិទ្យុការី AN- 24 បញ្ជាការដ្ឋានកងទ័ពជើងអាកាស
៩៥ - វរសេនីយ៍ទោ តូច សារី អត្តលេខ ០០៤.៥២៩ នាយផ្នែកបច្ចេកទេសយន្តហោះ បញ្ជាការដ្ឋានកងទ័ពជើងអាកាស
៩៦ - វរសេនីយ៍ទោ ប៉ូច យៀង អត្តលេខ ០០២.៤៩២ ប្រធានក្រុមហោះឧទ្ធម្ភាគចក្រ បញ្ជាការដ្ឋានកងទ័ពជើងអាកាស
៩៧ - វរសេនីយ៍ទោ ឆេព សុភារី អត្តលេខ ០០២.៤៩៣ ប្រធានក្រុមហោះឧទ្ធម្ភាគចក្រ បញ្ជាការដ្ឋានកងទ័ពជើងអាកាស
៩៨ - វរសេនីយ៍ទោ គាន់ ចាន់ថន អត្តលេខ ០០៤.៥៥៤ នាយរងការិយាល័យរដ្ឋបាល បញ្ជាការដ្ឋានកងទ័ពជើងអាកាស
៩៩ - វរសេនីយ៍ទោ សូ សុវណ្ណរតនៈ អត្តលេខ ០១៤២៦២ នាយរងលេខាធិការដ្ឋាន នាយកដ្ឋានប្រេងឥន្ធនៈ
១០០ - វរសេនីយ៍ត្រី គីម និត អត្តលេខ ០១៩៥៦២ នាយរងការិយាល័យសណ្តាប់ធ្នាប់ ខុទ្ទកាល័យក្រសួងការពារជាតិ
១០១ - វរសេនីយ៍ត្រី តៀក ប៊ុនឈឿន អត្តលេខ ០១៣៦៨៥ នាយផ្នែកបោះពុម្ពលេខាធិការដ្ឋាន ខុទ្ទកាល័យក្រសួងការពារជាតិ
១០២ - វរសេនីយ៍ត្រី ធុំ គន្ធារ អត្តលេខ ០១៣៧៧៣ នាយឃ្លាំងភ័ស្តុភារ ខុទ្ទកាល័យក្រសួងការពារជាតិ
១០៣ - វរសេនីយ៍ត្រី ម៉ម សុវណ្ណៈ អត្តលេខ ០០៨៦០៤ នាយសុខាភិបាល ខុទ្ទកាល័យក្រសួងការពារជាតិ
១០៤ - វរសេនីយ៍ត្រី សូ ចន អត្តលេខ ០០៨៦០៨ នាយវិស្វកម្ម ខុទ្ទកាល័យក្រសួងការពារជាតិ
១០៥ - វរសេនីយ៍ត្រី ប្រាក់ សុផាត អត្តលេខ ០០៨៦០៥ នាយយានដ្ឋាន ខុទ្ទកាល័យក្រសួងការពារជាតិ
១០៦ - វរសេនីយ៍ត្រី អ៊ុល ចណ្ណធី អត្តលេខ ០០៨៦០៦ នាយដឹកជញ្ជូន ខុទ្ទកាល័យក្រសួងការពារជាតិ
១០៧ - វរសេនីយ៍ត្រី អ៊ុន ស៊ីយឿន អត្តលេខ ០១២០៥៩ លេខាឯកឧត្តម អ៊ុន ដែន
១០៨ - វរសេនីយ៍ត្រី សោម ជោគ អត្តលេខ ០១៣៦៩២ នាយផ្នែកប្រេងឥន្ធនៈ ខុទ្ទកាល័យក្រសួងការពារជាតិ
១០៩ - វរសេនីយ៍ត្រី នួន ផល្លា អត្តលេខ ០១០៩២៤ ជំនួយការឯកឧត្តម ឆា ចំរ៉ាត់
១១០ - វរសេនីយ៍ត្រី យ៉ង់ សុទ្ធ អត្តលេខ ០១១៥៦៤ អង្គរក្សឯកឧត្តម ប៉ោ ប៊ុនស្រ៊ី
១១១ - វរសេនីយ៍ត្រី ជា សុធី អត្តលេខ ០១១៥៤៧ អង្គរក្សឯកឧត្តម ប៉ោ ប៊ុនស្រ៊ី
១១២ - វរសេនីយ៍ត្រី មុំ ឈាវធី អត្តលេខ ០១៤៤៤៦ ជំនួយការ ខុទ្ទកាល័យក្រសួងការពារជាតិ
១១៣ - វរសេនីយ៍ត្រី ធន់ វឿន អត្តលេខ ០១៣៦៩០ បំរើការផ្ទាល់ឯកឧត្តមទេសរដ្ឋមន្ត្រី ទៀ បាញ់
១១៤ - វរសេនីយ៍ត្រី ចាន់ ប៊ុត្រី អត្តលេខ ០១៣៧២៩ នាយផ្នែកគាមជានភ័ស្តុភារ-ហិរញ្ញវត្ថុ ខុទ្ទកាល័យក្រសួងការពារជាតិ
១១៥ - វរសេនីយ៍ត្រី អ៊ុំ ហេង អត្តលេខ ០១៣៧០៤ នាយផ្នែករដ្ឋបាលទីប្រឹក្សា ខុទ្ទកាល័យក្រសួងការពារជាតិ
១១៦ - វរសេនីយ៍ត្រី ម៉ែន ប៊ុនសុង អត្តលេខ ០០៨៣៦២ នាយផ្នែកគ្រប់គ្រងថវិការ ការិយាល័យហិរញ្ញវត្ថុ
ខុទ្ទកាល័យក្រសួងការពារជាតិ
១១៧ - វរសេនីយ៍ត្រី ឡាយ ម៉េងភន អត្តលេខ ០១៣៧០៨ នាយផ្នែកស្បៀង ការិយាល័យភ័ស្តុភារ ខុទ្ទកាល័យក្រសួងការពារជាតិ
១១៨ - វរសេនីយ៍ត្រី ឌិ ម៉េង អត្តលេខ ០០៨៦១០ អង្គរក្សឯកឧត្តម នួន សុខ
១១៩ - វរសេនីយ៍ត្រី ម៉ៅ ភាព អត្តលេខ ០០៨៣៦៦ ជំនួយការ ខុទ្ទកាល័យក្រសួងការពារជាតិ
១២០ - វរសេនីយ៍ត្រី ឡុង យុទ្ធ អត្តលេខ ០០៨៣៥២ ជំនួយការ ខុទ្ទកាល័យក្រសួងការពារជាតិ
១២១ - វរសេនីយ៍ត្រី អ៊ុក ស៊ីដេត អត្តលេខ ០១០៩២៨ លេខាផ្ទាល់ឯកឧត្តម អ៊ិន ចាន់ថា

១២២ - វរសេនីយ៍ត្រី ហុត ធឿន អត្តលេខ ០០៨៦៩១ ជំនួយការព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរត្ន

១២៣ - វរសេនីយ៍ត្រី ឌឹម ឌឹម អត្តលេខ ០១៣៨១៨ នាយផ្នែកសរសេរ នាយកដ្ឋានបុគ្គលិក

១២៤ - វរសេនីយ៍ត្រី ឌិម សុខា អត្តលេខ ០១៣៨៣០ នាយផ្នែកហានិភ្ភ័យសេក្តិ នាយកដ្ឋានបុគ្គលិក

១២៥ - វរសេនីយ៍ត្រី គង់ ពៅ អត្តលេខ ០១៣៨៤២ នាយផ្នែកវិវាទ នាយកដ្ឋានបុគ្គលិក

១២៦ - វរសេនីយ៍ត្រី សុខ សុផល អត្តលេខ ០១៣៨៣៨ នាយរងការិយាល័យអត្តសញ្ញាណប័ណ្ណ នាយកដ្ឋានបុគ្គលិក

១២៧ - វរសេនីយ៍ត្រី ប៉ែន សិរីមុន្នី អត្តលេខ ០០៨៥៧១ នាយផ្នែកសិក្សាគំរោង នាយកដ្ឋានបុគ្គលិក

១២៨ - វរសេនីយ៍ត្រី អ៊ុន រស់ អត្តលេខ ០១៣៨២២ នាយបុគ្គលិក នាយកដ្ឋានបុគ្គលិក

១២៩ - វរសេនីយ៍ត្រី គួច សុជាតិ អត្តលេខ ០១៣៨២៧ នាយរងការិយាល័យផែនការ នាយកដ្ឋានបុគ្គលិក

១៣០ - វរសេនីយ៍ត្រី តែច សុខគៀត អត្តលេខ ០២៤៦៧៨ នាយរងលេខាធិការដ្ឋាន នាយកដ្ឋានបុគ្គលិក

១៣១ - វរសេនីយ៍ត្រី ព្រហ្ម ចិន្តឫទ្ធី អត្តលេខ ០១៣៨១៤ នាយផ្នែកបុគ្គលិកស៊ីវិល នាយកដ្ឋានបុគ្គលិក

១៣២ - វរសេនីយ៍ត្រី គាន់ រស្មី អត្តលេខ ០១៣៨៣៩ នាយផ្នែកគ្រប់គ្រងទាហានបំរុង នាយកដ្ឋានបុគ្គលិក

១៣៣ - វរសេនីយ៍ត្រី បូ គឹមជួន អត្តលេខ ០១៣៨៣៧ នាយផ្នែកជ្រើសរើសនិងបណ្តុះបណ្តាល នាយកដ្ឋានបុគ្គលិក

១៣៤ - វរសេនីយ៍ត្រី យ៉ាស់ សុឃុន អត្តលេខ ០១៣៨២១ នាយរងការិយាល័យអត្តសញ្ញាណប័ណ្ណ នាយកដ្ឋានបុគ្គលិក

១៣៥ - វរសេនីយ៍ត្រី យ៉ុន សារិទ្ធ អត្តលេខ ០០៨៦៦៩ នាយផ្នែកសិក្សាគ្រប់គ្រងផ្សព្វផ្សាយ នាយកដ្ឋានបុគ្គលិក

១៣៦ - វរសេនីយ៍ត្រី ម៉ត សុគន្ធ អត្តលេខ ០១៣៧៩៧ នាយផ្នែកផែនការធ្វើពហុភាគី នាយកដ្ឋាននយោបាយផែនការ

១៣៧ - វរសេនីយ៍ត្រី ប៊ុច រដ្ឋរក្សា អត្តលេខ ០១៣៧៩៣ នាយហិរញ្ញវត្ថុ នាយកដ្ឋាននយោបាយផែនការ

១៣៨ - វរសេនីយ៍ត្រី អ៊ុត សារិទ្ធធី អត្តលេខ ០១៩៧៥១ នាយផ្នែកស្រាវជ្រាវពត៌មាន នាយកដ្ឋាននយោបាយផែនការ

១៣៩ - វរសេនីយ៍ត្រី ស៊ុន ដារិទ្ធិ អត្តលេខ ០៣៣៤១៧ នាយផ្នែកទាក់ទងកិច្ចការក្នុងអាស៊ាន នាយកដ្ឋាននយោបាយផែនការ

១៤០ - វរសេនីយ៍ត្រី មួច ស៊ីផាន អត្តលេខ ០២៤៦៦៨ នាយផ្នែកទាក់ទងវិទ្យាស្ថានសហគមន៍ នាយកដ្ឋាននយោបាយផែនការ

១៤១ - វរសេនីយ៍ត្រី ម៉ាស រ៉ា អត្តលេខ ០១៣៨០០ នាយផ្នែកសហប្រតិបត្តិការបច្ចេកទេសសេដ្ឋកិច្ច នាយកដ្ឋាននយោបាយផែនការ

១៤២ - វរសេនីយ៍ត្រី ផាត និល អត្តលេខ ០១៣៨២០ នាយបុគ្គលិក នាយកដ្ឋាននីតិកម្ម

១៤៣ - វរសេនីយ៍ត្រី ឌិត អាំម៉ារ៉ូ អត្តលេខ ០១៣៨២៩ នាយរងលេខាធិការដ្ឋាន នាយកដ្ឋាននីតិកម្ម

១៤៤ - វរសេនីយ៍ត្រី សរ សូត្រ អត្តលេខ ០០៨៤៣៩ នាយផ្នែកទ័ពអាកាស នាយកដ្ឋានអធិការកិច្ចទូទៅ

១៤៥ - វរសេនីយ៍ត្រី ប៉ែន ឋិ អត្តលេខ ០០៨៤៥២ នាយផ្នែកផែនការ នាយកដ្ឋានអធិការកិច្ចទូទៅ

១៤៦ - វរសេនីយ៍ត្រី សួស សុចណ្ណា អត្តលេខ ០០៨៥៧៤ នាយហិរញ្ញវត្ថុ នាយកដ្ឋានអធិការកិច្ចទូទៅ

១៤៧ - វរសេនីយ៍ត្រី ប៉ុល សារី អត្តលេខ ០០៨៤៤១ នាយផ្នែកភូមិភាគ នាយកដ្ឋានអធិការកិច្ចទូទៅ

១៤៨ - វរសេនីយ៍ត្រី ជា សុផល អត្តលេខ ០០៨៤៤២ នាយផ្នែកសរុប នាយកដ្ឋានអធិការកិច្ចទូទៅ

១៤៩ - វរសេនីយ៍ត្រី ម៉ៅ ធី អត្តលេខ ០១៤១៦៣ នាយផ្នែកកែតំរូវ នាយកដ្ឋានភូមិសាស្ត្រ

១៥០ - វរសេនីយ៍ត្រី ម៉ៅ សុផា អត្តលេខ ០២៥១៣៥ នាយរងលេខាធិការដ្ឋាន នាយកដ្ឋានភូមិសាស្ត្រ

១៥១ - វរសេនីយ៍ត្រី សារិន សារ៉ែត អត្តលេខ ០១៤៣១៤ នាយផ្នែកអនុវត្តសាលក្រម ស្ថាប័នអយ្យការយោធា

១៥២ - វរសេនីយ៍ត្រី សរ សារ៉ែត អត្តលេខ ០២៥៣៤៤ នាយរងការិយាល័យក្រឡាបញ្ជី ស្ថាប័នតុលាការយោធា

១៥៣ - វរសេនីយ៍ត្រី សួន ពិសី អត្តលេខ ០០២៨៦៦ នាយរងការិយាល័យស្រាវជ្រាវវិទ្យាសាស្ត្របណ្ណាល័យ វិទ្យាស្ថានយោធាកម្ពុជា
១៥៤ - វរសេនីយ៍ត្រី ឆេត សារី អត្តលេខ ០១៦៧២៧ នាយរងការិយាល័យធានាហ្វឹកហ្វឺន វិទ្យាស្ថានយោធាកម្ពុជា
១៥៥ - វរសេនីយ៍ត្រី ជា ចិន្តា អត្តលេខ ០០៨៦៨៦ នាយរងគិលានដ្ឋាន វិទ្យាស្ថានយោធាកម្ពុជា
១៥៦ - វរសេនីយ៍ត្រី ឆោ រួន អត្តលេខ ០០៨៦៧៩ នាយរងការិយាល័យយោធាចារ្យវិស្វកម្ម វិទ្យាស្ថានយោធាកម្ពុជា
១៥៧ - វរសេនីយ៍ត្រី គួយ សារិន អត្តលេខ ០០៨៦៨៥ នាយរងការិយាល័យយោធាចារ្យវិទ្យុទាក់ទង វិទ្យាស្ថានយោធាកម្ពុជា
១៥៨ - វរសេនីយ៍ត្រី ហួត ចាន់តារាចុន អត្តលេខ ០១០២៥០ នាយរងការិយាល័យយោធាចារ្យគីមីសាស្ត្រ វិទ្យាស្ថានយោធាកម្ពុជា
១៥៩ - វរសេនីយ៍ត្រី លួយ លីចណ្ណ អត្តលេខ ០០៣៨៧៨ នាយរងការិយាល័យយោធាចារ្យកុំព្យូទ័រ វិទ្យាស្ថានយោធាកម្ពុជា
១៦០ - វរសេនីយ៍ត្រី ឡុង សារួន អត្តលេខ ០១០២៥២ យោធាចារ្យកីឡា វិទ្យាស្ថានយោធាកម្ពុជា
១៦១ - វរសេនីយ៍ត្រី ឌឹប ចំរើន អត្តលេខ ០០៨៦៩១ យោធាចារ្យការពារអាកាស វិទ្យាស្ថានយោធាកម្ពុជា
១៦២ - វរសេនីយ៍ត្រី ឡាំ ដារ៉ារិទ្ធ អត្តលេខ ០០៨៦៨១ យោធាចារ្យការពារអាកាស វិទ្យាស្ថានយោធាកម្ពុជា
១៦៣ - វរសេនីយ៍ត្រី គីច ផល្លី អត្តលេខ ០១០២៤៨ យោធាចារ្យប៉ានលេខា វិទ្យាស្ថានយោធាកម្ពុជា
១៦៤ - វរសេនីយ៍ត្រី យឹម ឫទ្ធី អត្តលេខ ០០៨៦៨២ នាយទាហានគ្រប់គ្រងវគ្គ វិទ្យាស្ថានយោធាកម្ពុជា
